ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:...១១...សរ

# សារាចរ

## ស្តីពី

## ការលុបការបង់ថ្លៃចំពោះប្រជាពលរដ្ឋលក់ដូរតាមកញ្ច្រែង កញ្ចើ ល្អី

អនុលោមតាមបទប្បញ្ញត្តិពាក់ព័ន្ធនឹងការគ្រប់គ្រងផ្សារនៅទូទាំងប្រទេស អាជីវករលក់ដូរក្នុងផ្សារមានកាតព្វកិច្ចបង់ចំណូលចូលថវិការាជធានី ខេត្ត ដែលមានជាអាទិ៍ ការបង់ភាស៊ី និងការបង់ថ្លៃជួល តូប រាន ស្តង់ និងកន្លែងលក់ដូរផ្សេងទៀត តាមការកំណត់នៅក្នុងសៀវភៅបន្ទុក ព្រមទាំងបង់ពន្ធដារតាមការកំណត់នៃច្បាប់។

ដោយយកចិត្តទុកដាក់ជាប្រចាំដល់ជីវភាពរបស់ប្រជាពលរដ្ឋ ក្នុងគោលបំណងកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់ជីវភាពរបស់ប្រជាពលរដ្ឋ ព្រមទាំងកែលម្អសេវាសាធារណៈជូនប្រជាពលរដ្ឋ រាជរដ្ឋាភិបាលសម្រេចលុបការបង់ភាស៊ី និងការបង់ថ្លៃផ្សេងៗទៀត ចំពោះការលក់ដូររបស់ប្រជាពលរដ្ឋ តាមកញ្ច្រែង កញ្ចើ ល្អី នៅតាមទីផ្សារទូទាំងប្រទេស។

ប្រជាពលរដ្ឋ ដែលលក់ដូរតាមកញ្ច្រែង កញ្ចើ ល្អី ត្រូវទទួលបានការអនុគ្រោះ និងការគាំពារ តាមគោលការណ៍ ដូចខាងក្រោម÷

### ក- ន័យរបស់ការលក់ដូរតាមកញ្ច្រែង កញ្ចើ ល្អី

សំដៅដល់ការលក់ដូរតាមកញ្ច្រែង កញ្ចើ ល្អី របស់ប្រជាពលរដ្ឋ និងមានចរិតលក្ខណៈ ដូចខាងក្រោម÷

- លក់ដូរតាមកញ្ច្រែង កញ្ចើ ល្អី តូចតាច នៅទីកន្លែងលក់ដូរ និងទីផ្សារទូទាំងប្រទេស
- លក់កសិផលពីដំណាំដាំដុះ និងផលពីដំណាំធម្មជាតិ
- កន្លែងលក់ដូរមានលក្ខណៈបណ្តោះអាសន្ន។

### ខ- ការផ្តល់ការអនុគ្រោះ និងការគាំពារ

ប្រជាពលរដ្ឋដែលលក់ដូរតាមកញ្ច្រែង កញ្ចើ ល្អី ត្រូវទទួលបានការអនុគ្រោះ និងការគាំពារ ដូចខាងក្រោម÷

- បញ្ឈប់ការបង់ភាស៊ី និងរាល់ការបង់ថ្លៃទាំងឡាយណា ពីកន្លែងលក់ដូរ និងនៅតាមទីផ្សារទាំងអស់
- ទទួលបានការធានាសន្តិសុខ សុវត្ថិភាព អនាម័យ និងបរិស្ថាន ប្រកបដោយការយកចិត្តទុកដាក់ខ្ពស់របស់អាជ្ញាធរមូលដ្ឋាន។

### គ- ការរៀបចំទីកន្លែង និងរចនាសម្ព័ន្ធលក់ដូរ

សាលារាជធានី ខេត្ត ត្រូវរៀបចំគម្រោងកន្លែងលក់ដូរ ឬផ្សារសម្រាប់អ្នកលក់ដូរតាមកញ្ច្រែង កញ្ជើ ល្អី និង អ្នកលក់ដូរក្រីក្រតូចតាច ដូចខាងក្រោម÷

- កំណត់គោលការណ៍លើការគ្រប់គ្រងលម្អិត ដើម្បីដាក់ឱ្យអនុវត្តជាបន្ទាន់ និងប្រកបដោយប្រសិទ្ធភាព
- ត្រូវរៀបចំឱ្យមានកន្លែងលក់ដូរឱ្យបានច្បាស់លាស់ នៅតាមរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ និងរហូតដល់ឃុំសង្កាត់ ក្នុងករណីមានតម្រូវការចាំបាច់ សម្រាប់ជូនប្រជាពលរដ្ឋ ដែលលក់ដូរតាមកញ្ច្រែង កញ្ជើ ល្អី និងអ្នកលក់ដូរក្រីក្រតូចតាច ដោយមិនមានការបង់ថ្លៃអ្វីទាំងអស់ ចំពោះកន្លែងលក់ដូរនេះ
- សាលារាជធានី ខេត្ត អាចផ្សារភ្ជាប់គម្រោងកន្លែងលក់ដូរតូចតាច ជាមួយគម្រោងវិនិយោគសាធារណៈរបស់ថ្នាក់ក្រោមជាតិ ដោយមិនតម្រូវឱ្យមានការបង់ថ្លៃចំពោះកន្លែងលក់ដូរ និងត្រូវជាផ្នែកសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ អនាម័យ និងបរិស្ថាន
- លក្ខណៈវិនិច្ឆ័យសម្រាប់អ្នកលក់ដូរក្រីក្រតូចតាច ត្រូវកំណត់ដោយសាលារាជធានី ខេត្ត។ អ្នកលក់ដូរតូចតាច សំដៅដល់អ្នកលក់ដូរ ដូចមានចែងក្នុងចំណុច ក នៃសារាចរនេះ និងរាប់បន្ថែមទាំងទំនិញធ្វើដោយដៃតូចតាចរបស់ប្រជាពលរដ្ឋក្រីក្រ មានជាអាទិ៍ ប្រឡៅគោ ខ្សែគោ ធ្មៀងបង្គី ជាដើម។

ទទួលបានសារាចរណែនាំនេះ គ្រប់ក្រសួង ស្ថាប័ន សាលារាជធានី ខេត្ត និងអង្គភាពពាក់ព័ន្ធទាំងអស់ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ៥ ឆ្នាំ ២០១៦

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

***កន្លែងទទួល÷***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
- *គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ*
- *គ្រប់សាលារាជធានី-ខេត្ត*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*